THE SCHOOL DISTRICT OF
PHILADELPHIA

**ការិយាល័យអគ្គនាយក**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D**
អគ្គនាយក

ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០២០

ជូនចំពោះ ក្រុមគ្រួសារ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ជាទីគោរព៖

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាបានប្រកាសនៅថ្ងៃនេះថា នឹងបិទសាលាទាំងអស់ រយៈពេលពីរសប្ដាហ៍ ចាប់ពីថ្ងៃច័ន្ទ ទី ១៦ រហូតដល់ថ្ងៃសុក្រ ទី ២៧ ខែមីនា ឆ្នាំ ២០២០។

**ទោះបីជាក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) នៅតែគ្មានករណី សង្ស័យ ឬ ដឹងច្បាស់ ថាមានអ្នកផ្ទុកមេរោគ ខូវីដ-១៩ (មេរោគខូរ៉ូណា) នៅក្នុង សាលារៀន ឬ ការិយាល័យ ក៏ដោយ** ការបិទសាលាបានក្លាយជាការចាំបាច់ ដោយសារតំបន់ជិតខាងដែលបុគ្គលិករបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាជាច្រើនរស់នៅ ត្រូវបានគេសុំឱ្យចៀសវាងការធ្វើដំណើរដែលមិនចាំបាច់ និង មិនបាច់ឱ្យមកធ្វើការទេ។ បញ្ហានេះបានបង្កើតឱ្យមានបញ្ហាខ្វះបុគ្គលិកសម្រាប់សាលារបស់យើង។ សិស្សានុសិស្សមិនបាច់ទៅសាលារៀនទេក្នុងរយៈពេលពីសប្ដាហ៍នេះ។ នៅក្នុងអំឡុងពេលនេះ គេនឹងសម្អាតសាលារៀនរបស់ក្រសួងទាំងអស់ មុនពេលការវិលត្រឡប់របស់ សិស្សានុសិស្ស និង បុគ្គលិក។ យើងនឹងធ្វើការប្រាស្រ័យទាក់ទងបន្តទៅក្រុមគ្រួសារនៅក្នុងអំឡុងពេលនេះ ដើម្បីឱ្យពួកគាត់ជ្រាប់ពីព័ត៌មានថ្មីៗ និង ពីជំហានបន្ទាប់។

ក្នុងខណៈពេលដែលគេកំពុងគិតគូរពី ផលប៉ះពាល់ និង ព័ត៌មានលម្អិត នៃការបិទសាលារយៈពេលពីរសប្ដាហ៍នេះ គេជំរុញឱ្យសិស្សានុសិស្ស យក សម្ភារៈផ្ទាល់ខ្លួន ថ្នាំពេទ្យ និង អ្វីៗដែលពួកគេនឹងត្រូវការក្នុងអំឡុងពេលបិទសាលានេះ ទៅផ្ទះ។

យើងដឹងថាផលវិបាកនៃការបិទសាលាទូទាំងក្រសួងនេះ អាចផ្ដល់ការលំបាកដល់ក្រុមគ្រួសារ។ ក្រសួងអប់រំកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយការិយាល័យ គ្រប់គ្រងគ្រោះអាសន្ន និង ក្រសួងផ្នែកសុខភាពសាធារណៈ នៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ដើម្បីរៀបចំផែនការអនុវត្តឱ្យបានច្រើនទៅតាមការដែលអាចធ្វើទៅបាន ដើម្បីរក្សាឱ្យបាននូវជំនួយនៃការបម្រើសំខាន់ៗ ដែលសាលារបស់យើងផ្ដល់ជូនដល់ សិស្សានុសិស្ស និង ក្រុមគ្រួសារ។ សូមចូលមើលវ៉ិបសៃ www.philasd.org ដើម្បីជ្រាបពីបញ្ជីនៃការបម្រើថ្មីៗ ដែលគេផ្ដល់ជូនទូទាំងទីក្រុង រួមទាំង ម្ហូបអាហារ និង ឱកាសលេងកម្សាន្ត។

ដើម្បីជ្រាបពីព័ត៌មានថ្មីៗអំពីស្ថានភាពនៃការប្រែប្រួល សូមចូលមើលវ៉ិបសៃ www.philasd.org/coronavirus។ យើងនឹងបន្តផ្ដល់ ព័ត៌មានថ្មីៗជូនលោកអ្នក នៅពេលផែនការមានការវិវឌ្ឍន៍។

សូមអរគុណចំពោះការគាំទ្រ និងភាពជាដៃគូរបស់លោកអ្នក ក្នុងអំឡុងពេលដ៏សំខាន់នេះ។

ដោយសេចក្ដីគោរពរាប់អាន

William R. Hite/fw

William R. Hite Jr., Ed.D.
អគ្គនាយក
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា